**សាលា LOWELL PUBLIC SCHOOLS**

Henry J. Mroz Central Administration Offices
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី17 ខែមេសា ឆ្នាំ2020

គោរពជូនគ្រួសារសាលា Lowell Public Schools,

យើងសង្ឃឹមថា អ្នកនឹងអ្នកជាទីស្រឡាញ់របស់អ្នកកំពុងមានសុវត្ថិភាព និង មានសុភាពល្អ នៅក្នុងពេលដ៏លំបាកនេះ។ បន្ថិតទៀត យើងនឹងចូលដល់សប្តាហ៍ទី 6 នៃបិទសាលាដោយសារជម្ងឺរាតត្បាត COVID-19 ។ នៅក្រោមកាលៈទេសៈធម្មតា យើងនឹងត្រៀមខ្លួនសម្រាប់វិស្សមកាលនៅខែមេសា ដោយរំពឹងទុកជាមុននូវដំណើរកម្សាន្តជាលក្ខណៈគ្រួសារ ទស្សនាការរត់ម៉ារ៉ាតុងនៅ Boston ឬក៏រីករាយនឹងការសម្រាក និង បន្ធូរអារម្មណ៍ខ្លះ។ ជាអកុសល ទាំងអស់នេះគឺមិនមែនជាកាលៈទេសៈធម្មតាឡើយ។ ដោយសារមានការបង្អាក់ជាច្រើន ដែលគ្រួសាររបស់យើងបានប្រឈមមុខនៅអំឡុងស្ថានភាពនេះ យើងបានធ្វើការសម្រេចចិត្តដើម្បីបន្តការបង្ហាត់បង្រៀនពីចម្ងាយនៅសប្តាហ៍ក្រោយ ដើម្បីធានាតម្រូវការចាំចាច់នៃការបន្តទម្លាប់ និង គំរូដែលពួកអ្នកភាគច្រើនបានបង្កើតដើម្បីគាំទ្រការរៀនសូត្រពីពីផ្ទះ។ ការណែនាំឲ្យបន្តការរៀនសូត្រពីចម្ងាយរហូតពេញមួយវិស្សមកាលនៃខែមេសា ត្រូវបានធ្វើឡើង បន្ទាប់ពីប្រឹក្សាជាមួយនឹងភាគីពាក់ព័ន្ធជាច្រើន ហើយការសម្រេចនេះត្រូវបានឯកភាពនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសាលានៅថ្ងៃទី15 ខែមេសា។

ថ្ងៃច័ន្ទ ទី20 គឺជាទិវាអ្នកស្នេហាជាតិ ដែលជាថ្ងៃសម្រាករបស់រដ្ឋ ហើយនឹងនៅត្រូវបានប្រារព្ធជា “ថ្ងៃឈប់សម្រាក” ពីសាលា។ ដូច្នេះគ្រប់សាលា និង គ្រប់ការិយាល័យសង្កាត់ នឹងត្រូវបានបិទនៅថ្ងៃច័ន្ទ ហើយបន្ទាប់មក ការរៀនសូត្រពីចម្ងាយនឹងបន្តសម្រាប់រយៈពេលសប្តាហ៍ដែលនៅសល់ គឺពីថ្ងៃអង្គារ ដល់ ថ្ងៃសុក្រ (ថ្ងៃទី21-24 ខែមេសា)។ សូមកត់សម្គាល់ថា សេវាកម្មអាហារនឹងបន្តតាមពេល និង ទីតាំងដែលបានកំណត់នៅសប្តាហ៍ក្រោយ សូម្បីតែថ្ងៃច័ន្ទក៏ដោយ។ បញ្ជីទាំងមូលនៃទីតាំង និង ពេលវេលាសម្រាប់សេវាកម្មអាហារអាចរកបាននៅក្នុងគេហទំព័ររបស់សង្កាត់នេះ។

នៅថ្ងៃច័ន្ទ ទី6 ខែមេសា យើងបានផ្លាស់ប្តូរកម្មវិធីអប់រំរបស់យើងពីសកម្មភាពរៀនសូត្រនៅផ្ទះតាមការជ្រើសរើស ទៅកាន់ផែនការរៀនសូត្រពីចម្ងាយដែលរួមមានកិច្ចការចាំបាច់ត្រូវធ្វើ ដែលនឹងត្រូវបានចាត់ចំណាត់ថ្នាក់ និង កត់ត្រាទុកនៅក្នុងប័ណ្ណរបាយការណ៍សាលា។ ប្រព័ន្ធចាត់ចំណាត់ថ្នាក់របស់យើងនឹងអនុវត្តតាមការណែនាំរបស់នាយកដ្ឋានអប់រំបឋម និង មធ្យមសិក្សារដ្ឋ Massachusetts (DESE) ដើម្បីផ្លាស់ប្តូរទៅកាន់ប្រព័ន្ធ “ក្រឌិត/គ្មានក្រេឌីត” ជំនួសឲ្យពិន្ទុពី 0-100 តាមទម្លាប់។

យើងទទួលស្គាល់ ជាពិសេសនៅកម្រិតមធ្យមសិក្សា ថា ដោយការផ្លាស់ទៅកាន់ប្រព័ន្ធចាត់ចំណាត់ថ្នាក់ពិន្ទុជា "ក្រេឌីត/គ្មានក្រេឌីត" យើងនឹងចាំបាច់ត្រូវដោះស្រាយបញ្ហានៃការគណនាមធ្យមភាគ (GPA) ដែលកំណត់បញ្ជីសិស្សពូកែ កំណត់សម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីកិត្តិយស និង អាហារូបករណ៍ជាក់លាក់មួយចំនួន។ យើងនឹងបន្តជូនដំណឹងដល់អ្នក នៅពេលការណែនាំត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាទាក់ទងនឹង GPA ទាំងនេះ។

នៅអំឡុងពេលនៃការរៀនសូត្រពីចម្ងាយ យើងស្នើឲ្យសិស្សទាំងអស់ចូលរួមក្នុងការរៀនសូត្រពីចម្ងាយប្រកបដោយគោលបំណង និង មានលទ្ធផលសម្រាប់រយៈពេលប្រហែលពាក់កណ្តាលនៃថ្ងៃរៀនសូត្រធម្មតា (ពី 3 ទៅ 3.5 ម៉ោង)។ រឿងនេះអាចសម្រេចបានតាមរយៈការរួមផ្សំនៃសកម្មភាពសិស្សដោយឯករាជ្យ និង សកម្មភាពដែលដឹកនាំដោយគ្រូ។ ផែនការរៀនសូត្រតាមកម្រិតថ្នាក់ និង ការណែនាំត្រូវបានបង្ហោះផ្សាយនៅក្នុងគេហទំព័ររបស់សង្កាត់នេះ។ សាលារបស់យើងបាននិងកំពុងទាក់ទងទៅកាន់គ្រួសារ នៅអំឡុងពេលនៃការអនុវត្តការរៀនសូត្រពីចម្ងាយ។ ប្រសិនបើអ្នកមិនបានទាក់ទងសាលារបស់អ្នកទេ សូមហៅទូរស័ព្ទទៅកាន់សាលារបស់អ្នកដោយផ្ទាល់ និង ត្រូវប្រាកដថាព័ត៌មានសម្រាប់ទំនាក់ទំនងរបស់អ្នកគឺស្ថិតនៅពេលបច្ចុប្បន្ននេះ។

យើងទទួលស្គាល់ថា ការរៀនសូត្រពីចម្ងាយមិនអាចដូចគ្នានឹងថ្ងៃរៀននៅសាលាតាមធម្មតាបានឡើយ ប៉ុន្តែយើងនៅតែប្តេជ្ញាក្នុងការផ្តល់បទពិសោធន៍ការរៀនសូត្រប្រកបដោយអត្ថន័យ ជូនដល់គ្រប់សិស្ស LPS ទាំងអស់តាមរបៀបដែលគួរតែបញ្ជៀបមោទនភាពជាច្រើននៅទូទាំងសហគមន៍ Lowell ។ គ្រូ មេដឹកនាំសាលា និង បុគ្គលិកនៅសាលានីមួយៗរបស់យើងមានដឹងគុណរបស់ខ្ញុំជាបន្ត ដូចគ្នានឹងឪពុកម្តាយ និង សមាជិកគ្រួសារដែលកំពុងគាំទ្រសិស្សរបស់យើង នៅក្រោមកាលៈទេសៈដ៏ពិបាកយ៉ាងខ្លាំងទាំងនេះ។

បុគ្គលិកសាលារបស់យើងកំពុងបន្តទាក់ទងទៅកាន់គ្រួសារនានា ដើម្បីកំណត់លទ្ធភាពរបស់ពួកគេក្នុងការប្រើប្រាស់អ៊ីនធើណេត និង ឧបករណ៍បច្ចេកវិទ្យា ដែលត្រូវចាំបាច់សម្រាប់ការចូលរួមក្នុងកម្មវិធីសិក្សាពីចម្ងាយ។ សូមទាក់ទងសាលារបស់អ្នក ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងតម្រូវការពីការរៀនសូត្រពីចម្ងាយដូចជាការលទ្ធភាពចូលទៅប្រើប្រាស់ឧបករណ៍ ឬ អ៊ីនធើណេត។

កំណត់សម្គាល់មួយចំនួនបន្ថែមទៀតត្រូវបានរៀបរាប់ខាងក្រោម ហើយយើងនឹងបន្តផ្តល់ជូនអ្នកនូវបច្ចុប្បន្នភាព នៅពេលព័ត៌មានថ្មីកើតមានឡើង៖

- DESE បានប្រកាសថា លក្ខខណ្ឌទាមទារសម្រាប់ការធ្វើតេស្តតាម (MCAS) ត្រូវបានលើកលែងហើយសម្រាប់ឆ្នាំសិក្សា 2019-2020។ វាមានន័យថា សិស្សរបស់យើងនៅក្នុងថ្នាក់ទី 3-10 នឹងមិនទទួលការធ្វើតេស្តតាមស្តង់ដាររដ្ឋ ដែលត្រូវបានគ្រោងនឹងធ្វើឡើងនៅនិទាឃរដូវនេះ។ ជាងនេះទៅទៀត លក្ខខណ្ឌទាមទារសមត្ថភាពសម្រាប់សាលាវិទ្យាល័យ ដោយផ្អែកលើលទ្ធផល MCAS អាចត្រូវបានកែប្រែ ឬ លើកលែងសម្រាប់ឆ្នាំនេះ។

- ពិធីប្រគល់សញ្ញាប័ត្រថ្នាក់វិទ្យាល័យត្រូវបានគ្រោងធ្វើឡើងនាពេលថ្មីនេះនៅឆ្នាំសិក្សា 2019-2020 នៅថ្ងៃទី3 មិថុនា។ ជាមួយនឹងស្ថានភាពកំពុងកើតមានឡើងនាពេលបច្ចុប្បន្ននេះ ថ្ងៃទី24 មិថុនា ត្រូវបានកំណត់ថាជាកាលបរិច្ឆេទយថាភាពតាមដែលអាចទៅរួច។ ថ្នាក់ដឹកនាំសាលាវិទ្យាល័យ Lowell ក៏កំពុងជួបប្រជុំគ្នាផងដែរជាមួយនឹងមន្ត្រីថ្នាក់រៀនដើម្បីកំណត់កាលបរិច្ឆេទយថាភាព និង គ្រោងរៀបចំសម្រាប់ពិធីរំរែកនៅសាលាសម្រាប់ការបញ្ចប់ថ្នាក់វិទ្យាល័យ។

- រយៈពេលចុះឈ្មោះសម្រាប់ថ្នាក់កុមារដ្ឋាន និង ថ្នាក់មតេយ្យត្រូវបានពន្យាពេល ហើយការិយាល័យធនធានគ្រួសារថ្មីៗនេះកំពុងរុករកវិធីដើម្បីបន្តការចុះឈ្មោះ តាមរបៀបដែលមានសុវត្ថិភាព និង មានប្រសិទ្ធិភាព តាមដែលអាចធ្វើបាន។ យើងនឹងផ្តល់ជូនអ្នកនូវព័ត៌មានលម្អិត នៅពេលកាលបរិច្ឆេទចុះឈ្មោះថ្មីត្រូវបានកំណត់រួចរាល់។

យើងនឹងបន្តនៅទីនេះសម្រាប់អ្នក នៅអំឡុងពេលនៃការលំបាកនេះ ហើយនឹងបន្តផ្តល់ព័ត៌មានថ្មីៗដល់អ្នកពេញមួយស្ថានភាពនេះ។ នៅចន្លោះពេលនេះ ប្រសិនបើអ្នកត្រូវការជំនួយបន្ថែមទៀត អ្នកអាចហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទគោលរបស់សាលាអ្នក ឬ មជ្ឈមណ្ឌលធនធានគ្រួសារ តាមលេខ 978-674-4321 ។ អ្នកក៏អាចដាក់ជូននូវសំណួររបស់អ្នក ឬ សំណើររបស់អ្នកតាមរយៈពាក្យតាមអ៊ីនធើណេត៖
https://docs.google.com/forms/d/e/1FAIpQLSe3Md1leOCZiQ2bi2enmSvUXvROSnPVDPTIs9nmIdFPq3wl5Q/viewform

សូមបន្តមានសុខភាពល្អ និង មានសុវត្ថិភាព។

ដោយក្តីស្មោះត្រង់,

Dr. Joel D. Boyd
អ្នកមើលការខុសត្រូវសាលា